**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ :** ៤៧៦៤ **អយក.**ស៧

រាជធានីភ្នំពេញ.ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**ជម្រាបជូន**
**លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

**កម្មវត្ថុ :** សំណើសុំផ្សព្វផ្សាយពាក្យស្លោកនៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ
**យោង :** លិខិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០

តតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជំរាបលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាជ្រាបថាពាក្យស្លោកដែលលោកបានសុំផ្សព្វផ្សាយនៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅនោះ អាចផ្សព្វផ្សាយបានលុះណាតែកែសំរួលដោយច្រចាច់ខ្លឹមសារបញ្ចូលគ្នាឱ្យនៅត្រឹមតែពីរគឺ

ស្លោកទី១ : " **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា** " ។

ស្លោកទី២ : "**រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍** " ។

ម្យ៉ាងទៀតការបិទផ្សព្វផ្សាយពាក្យស្លោកទាំងពីរខាងលើជាសាធារណៈនៅខាងក្រៅរបងសាលារៀនដើម្បីឱ្យមហាជនមើលឃើញនោះត្រូវតែសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃជាមុនសិន ព្រមទាំងបញ្ជាក់ពីពេលវេលានៃការបិទពាក្យស្លោកផ្សព្វផ្សាយនេះឱ្យបានច្បាស់លាស់ ។

អាស្រ័យហេតុនេះសូមលោកនាយកអនុវត្តតាមខ្លឹមសារដូចមានចែងខាងលើ ។

សូមលោកនាយកទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា**
**អនុរដ្ឋលេខាធិការ**

**ធន់_សារ៉ុម**

ចម្លងជូន
-សាលារាជធានី-ខេត្ត " ដើម្បីជ្រាប "
-មន្ទីររាជធានី-ខេត្ត " ដើម្បីជ្រាប "
-កាលប្បវត្តិ-ឯកសារនា-រប